**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**


<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១៤



ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 25-Sep-2014, 10:06
CMS/CFO: Sann Rada



<u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:


---

# ការឆ្លើយតបទៅនឹងចម្លើយតប របស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំឲ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១

---


**<u>ដាក់ដោយ៖</u>**

**ក្រុមមេធាវីការពារក្តី នួន ជា៖**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

លីវ សុវណ្ណា

Joshua ROSENSWEIG

Doreen CHEN

Xiaoyang NIE

**<u>ចម្លងជូន៖</u>**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

អនុលោមតាមវិធាន ១០៩(១) និង ១០៨(៧) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") និងមាត្រា ៨.៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ[1]មេធាវីការពារក្ដីរបស់ នួន ជា ("មេធាវីការពារក្ដី") តទៅនេះសូមដាក់ការឆ្លើយតបនេះទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើលើកទី១ និងទី២របស់លោក នួន ជា ស្នើសុំឱ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែម ("សំណើសុំពិចារណាទៅលើភស្តុតាងបន្ថែម") ពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីដែលនឹងត្រូវដាក់ក្នុងពេលឆាប់ៗខាងមុខនេះប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានដាក់សំណើសុំឱ្យពិចារណា និងទទួលយកភស្តុតាងបន្ថែមពាក់ព័ន្ធនឹងកិច្ចសម្ភាសន៍របស់ ថេត សម្បត្តិ ជាមួយវិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរដែលបានធ្វើឡើងនៅខែ សីហា ឆ្នាំ២០១៤ ("សំណើលើកទី១")[2]។ មេធាវីការពារក្ដីបានលើកឡើងថា (១) បទសម្ភាសន៍បានបង្ហាញអំពីភស្តុតាងដោះបន្ទុកទាក់ទងនឹងរចនាសម្ព័ន្ធរបស់ បកក និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់លោក នួន ជា ទៅលើឧក្រិដ្ឋកម្មដែលបានកើតមានឡើងនៅទួលពោធិ៍ជ្រៃ (២) ការបង្ហាញពីការជ្រៀតជ្រែកយ៉ាងជាក់ស្ដែងរបស់រដ្ឋាភិបាលមកលើលទ្ធភាពការពារក្ដីរបស់លោក នួន ជា[3]។ មេធាវីការពារក្ដីបានលើកឡើងទៀតថា បទសម្ភាសន៍បានបញ្ជាក់ពីបញ្ហាដែលថា សហនាយក និងសហផលិតករ ថេត សម្បត្តិ និង Rob Lemkin ដែលអ្នកទាំងពីរមានភស្តុតាងដោះបន្ទុកពាក់ព័ន្ធយ៉ាងខ្លាំង និងដោយផ្ទាល់។ មេធាវីការពារក្ដីបានស្នើសុំឱ្យទទួលយកជាភស្តុតាងនូវបទសម្ភាសន៍ជាសម្លេងរបស់ ថេត សម្បត្តិ និងបានស្នើសុំឱ្យតុលាការកំពូលកោះហៅ ថេត សម្បត្តិ និង Rob Lemkin មកផ្ដល់សក្ខីកម្ម និងស្វែងរកភស្តុតាងដោះបន្ទុកដែលអ្នកទាំងពីរមាន[4]។ នៅថ្ងៃទី០២ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានដាក់សណើលើកទី២ សុំឱ្យពិចារណាលើភស្តុតាងបន្ថែមទាក់ទងនិងបទសម្ភាសន៍របស់អតីត

---

[1] សេចក្ដីណែនាំអនុវត្ត អវតក/០១/២០០៧/វិ.០៧ "ការដាក់ឯកសារនៅចំពោះមុខអវតក"។

[2] ឯកសារលេខ **F2** "សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១", ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៤ ("សំណើលើកទី១")។

[3] សំណើលើកទី១ កថាខណ្ឌទី ១៤ ដល់ ១៦។

[4] សំណើលើកទី១ កថាខណ្ឌទី ១៧ ដល់ ១៨។

ចៅក្រមអង្គជំនុំជម្រះសាលាដំបូង Silvia Cartwright ដែលធ្វើឡើងនៅខែ វិច្ឆិកា ឆ្នាំ២០១៣ និង សៀវភៅដែលបោះពុម្ពដោយអតីតសហចៅក្រមស៊ើបអង្កេត Marcel Lemonde នៅខែ មករា ឆ្នាំ ២០១៣ ("សំណើលើកទី២")[5]។ មេធាវីការពារក្តីបានអះអាងថា បទសម្ភាសន៍របស់ចៅក្រម Cartwright បានបង្ហាញថា ចៅក្រមជាតិនៅអង្គជំនុំជម្រះសាលាដំបូងមានភាពលម្អៀងដោយសារតែបទពិសោធន៍របស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយឡែកសៀវភៅរបស់ចៅក្រម Lemonde បានបង្ហាញអំពីការជ្រៀតជ្រែកយ៉ាងជាក់ស្តែងរបស់រដ្ឋាភិបាលមកក្នុងដំណើរការអវតក។ សំណើលើកទី២ បានស្នើសុំឱ្យទទួលយកជាភស្តុតាងនូវកិច្ចសម្ភាសន៍ជារូបភាពនៃកិច្ចសម្ភាសន៍របស់ចៅក្រម Cartwright និង ផ្នែកដកស្រង់ដែលបានជ្រើសរើសចេញពីសៀវភៅរបស់ចៅក្រម Lemonde[6]។ នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ មេធាវីការពារក្តីរបស់ ខៀវ សំផន បានចូលរួមជាមួយសំណើទាំងពីរ[7]។

2. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបមួយ ("ចម្លើយតប")[8]។ ក្នុងចំណោមនោះសហព្រះរាជអាជ្ញាបានអះអាងថា ការព្យាយាមកន្លងមកក្នុងការកោះហៅ ថេត សម្បត្តិ និង Lemkin ក្នុងការទទួលយកភស្តុតាងដែលខ្លួនមានគឺមិនជោគជ័យ[9] និងថាមេធាវីការពារក្តីខកខានក្នុងការបង្ហាញពីទំនាក់ទំនងរវាង ថេត សម្បត្តិ និង នួន ជា បើទោះជាខ្លួនបានទទួលស្គាល់ថា ថេត សម្បត្តិ បាននិយាយជាសាធារណៈសុំឱ្យចោទប្រកាន់ នួន ជា លើឧក្រិដ្ឋកម្ម តែមិនមែននៅទួលពោធិ៍ជ្រៃនោះទេ[10]។ សហព្រះរាជអាជ្ញាអះអាងដល់អង្គជំនុំជម្រះថាទាំង ថេត

---

[5] ឯកសារលេខ **F2/2** "សំណើទីពីរស្នើសុំឱ្យពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី០២ ខែ កញ្ញា ឆ្នាំ ២០១៤ ("សំណើលើកទី២")។

[6] សំណើលើកទី២ កថាខណ្ឌ ១៣ ដល់ ១៩។

[7] ឯកសារលេខ **F2/1/1** , 'Soutien de la Défense de M. KHIEU Samphan aux deux premières requêtes de la Défense de M. NUON Chea aux fins d'admission et d'examen de moyens de prevue supplémentaires en appeal (F2 et F2/1)' ថ្ងៃទី០៨ ខែ កញ្ញា ឆ្នាំ ២០១៤។

[8] ឯកសារលេខ **F2/2** "ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើទីមួយ និងទីពីររបស់មេធាវីការពារក្តី នួន ជា សុំឱ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១៤ (ចម្លើយតប)។

[9] ចម្លើយតប កថាខណ្ឌ ៧ ដល់ ៨។

[10] ចម្លើយតប កថាខណ្ឌ ១០ ដល់ ១១, ១៣។

សម្បត្តិ និង Lemkin បានយល់ខុសទៅនឹងភស្តុតាងដែលសហព្រះរាជអាជ្ញាមិនដែលបានឃើញ ដែលភស្តុតាងទាំងនោះនឹង"ច្បាស់"ជា"ភស្តុតាងដាក់បន្ទុកយ៉ាងខ្លាំង"[11]។ ដោយយោងតាមសហព្រះរាជអាជ្ញាដែលអះអាងថា វាមិនមានការចាំបាច់អីទេ សម្រាប់អង្គជំនុំជម្រះនេះក្នុងការទទួលយកភស្តុតាងដែលទាក់ទងនឹងបទចោទដែលខ្លួនកំពុងគ្រប់គ្រង ពីព្រោះថាអង្គជំនុំជម្រះវិនិច្ឆ័យផ្សេងគ្នា ក្នុងសវនាការផ្សេងគ្នាអាចនៅពេលណាមួយក្នុងពេលខាងមុខធ្វើដូច្នេះបានក្នុងនាមអង្គជំនុំជម្រះតុលាកំពូល[12]។ សហព្រះរាជអាជ្ញាបានជំទាស់ដូចគ្នានេះដែរទៅនឹងសំណើសុំឱ្យទទួលយកជាភស្តុតាងនៃបទសម្ភាសន៍ចៅក្រម Cartwright និង សៀវភៅរបស់ចៅក្រម Lemonde[13]។

3. ការលើកឡើងរបស់សហព្រះរាជអាជ្ញាទៅលើព័ត៌មាននៃបទសម្ភាសន៍របស់ ថេត សម្បត្តិ និង ការព្យាយាមរបស់តុលាការនាពេលកន្លងមកក្នុងការទទួលយកភស្តុតាង គឺមិនត្រឹមត្រូវទេ។ សហព្រះរាជអាជ្ញាបានលើកឡើងថា សំណើលើកទី១ "បង្ហាញខុសថា [...] អង្គជំនុំជម្រះសាលាដំបូងមិនបានខិតខំប្រឹងប្រែងក្នុងការទទួលយកភស្តុតាងរបស់ ថេត សម្បត្តិ" ក៏ប៉ុន្តែសហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញពីការព្យាយាមសូម្បីតែមួយរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលបានសក្ខីកម្មរបស់ ថេត សម្បត្តិ ឬភាពយន្តឯកសារដែលគាត់មាន[14]។ សហព្រះរាជអាជ្ញាមិនបាននិយាយពីចេតនារបស់ Lemkin ក្នុងការពិភាក្សា ឬក៏បង្ហាញពីភាពយន្តឯកសារក្នុងពេលសវនាការ[15]។ សហព្រះរាជអាជ្ញាបានលើកឡើងខុសបន្តទៀតទៅលើលក្ខណៈនៃបទសម្ភាសន៍របស់

---

[11] ចម្លើយតប កថាខណ្ឌ ១៤។

[12] ចម្លើយតប កថាខណ្ឌ ១៥។

[13] ចម្លើយតប កថាខណ្ឌ ១៧-២៤។

[14] ចម្លើយតប កថាខណ្ឌ ៧-៩។ សហព្រះរាជអាជ្ញាបានបង្ហាញតែការព្យាយាមមួយគត់ក្នុងការទាក់ទងជាមួយ ថេត សម្បត្តិ ក្នុងអឡុងពេលសវនាការ ដែលជាផ្នែកមួយនៃការព្យាយាមទទួលបានព័ត៌មានសម្រាប់ទំនាក់ទំនងនៃសាក្សីសក្តានុពលផ្សេងទៀត។ សូមមើលចម្លើយតបនៅជើងទំព័រ១៤។ ឯកសារលេខ **E292/1/2** អនុស្សារណៈរបស់អង្គភាពគាំពារសាក្សី ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ ២០១៣។ ក្នុងការលើកនោះ អង្គភាពគាំពារសាក្សី ទំនងជា "មិនអាចទទួលអាសយដ្ឋានអ៊ីម៉ែល ឬក៏ព័ត៌មានទំនាក់ទំនងលម្អិតផ្សេងទៀត" បើទោះជាតាមរយៈសារព័តមាននៅពេញទីក្រុងភ្នំពេញហាក់ដូចជាគ្មានការលំបាកអ្វីសោះក្នុងការធ្វើដូច្នេះ ហើយអាសយដ្ឋានទំនាក់ទំនងរបស់ Lemkin អាចរកបាន។

[15] ឯកសារ **E294** "សំណើសុំទទួលយកភស្តុតាងថ្មី កោះហៅ Rob Lemkin និងចាប់ផ្តើមការស៊ើបអង្កេត" ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣, កថខណ្ឌ ១១។

ថេត សម្បត្តិ។ បញ្ហានោះគឺមិនមែន"មតិផ្ទាល់ខ្លួន" របស់ ថេត សម្បត្តិ នោះទេ[16] ក៏ប៉ុន្តែវាជាការរៀបរាប់របស់គាត់អំពីភស្តុតាងដែលគាត់ទទួលបានពីប្រភពសំខាន់[17]។ សាលក្រមក្នុងសំណុំរឿង ០០២/០១ បានពឹងផ្អែកយ៉ាងច្រើន មិនត្រឹមតែទៅលើការរៀបរាប់ដោយគ្មានប្រភពច្បាស់លាស់របស់បុគ្គលទីបីប៉ុណ្ណោះទេ[18] ប៉ុន្តែថែមទាំងពឹងផ្អែកផងដែរទៅលើការវាយតម្លៃយ៉ាងទូលំទូលាយទៅលើការស្រាវជ្រាវជាបឋមដែលផ្តល់ដោយសាក្សី[19]។ ការពិពណ៌នាអំពីភស្តុតាងដែលពាក់ព័ន្ធដែលផ្តល់ដោយ ថេត សម្បត្តិ ឬ Lemkin ទៅលើប្រធានបទដែលបានកំណត់ឡើងយ៉ាងច្បាស់ដែលអ្នកទាំងពីរបានចំណាយពេល"ជាច្រើនឆ្នាំ"[20] ក្នុងការស៊ើបអង្កេតគឺយ៉ាងហោចណាស់អាចជឿជាក់បាន។ មេធាវីការពារក្តីយល់ស្របយ៉ាងពេញទំហឹងជាមួយសហព្រះរាជអាជ្ញាថា ការទទួលយកភាពយន្តឯកសារគឺ ជាការត្រឹមត្រូវ[21] អាស្រ័យហេតុនេះមានការឆ្ងល់អំពីការជំទាស់របស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់មេធាវីការពារក្តី ដែលស្នើដល់អង្គជំនុំជម្រះនេះឱ្យទទួលយកជាភស្តុតាង[22]។ ក្នុងលក្ខខណ្ឌអប្បបរិមា គ្មានហេតុផលសមស្របណាមួយហាមឃាត់មិនឱ្យស្វះស្វែងរកពីលទ្ធភាពដែល ថេត សម្បត្តិ និង/ឬ Lemkin អាចបញ្ជាក់អំពីការពិពណ៌នារបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះឡើយ[23]។

---

[16] ចម្លើយតប កថាខណ្ឌ ៦។

[17] សំណើលើកទី១ កថាខណ្ឌ ៦ (អ្នកត្រូវបានគេសម្ភាស "បានសារភាពថា បានប្រព្រឹត្តប្រឆាំងនិង ប៉ុល ពត និង នួន ជា។ ប្រធានសន្តិសុខ អ្នកគ្រប់គ្រង និង ចារជន "បានប្រាប់ខ្ញុំអំពីគម្រោងការទាំងអស់" មានដូចជា រាប់ទាំងការបញ្ជាឱ្យ "សម្លាប់ទាហានបើកបរយន្តហោះ")។

[18] សូមមើលឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១២៤។

[19] សូមមើលឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, ជើងទំព័រ ៣១៨, ៣៣៥, ៣៤៤, ២៦៥៣, ២៦៥៧។ ។

[20] សំណើលើកទី១ កថាខណ្ឌ ៣។

[21] សំណើលើកទី១ កថាខណ្ឌ ១៧ (ស្នើសុំឱ្យមានការស៊ើបអង្កេតលើភាពយន្តឯកសាររបស់ ថេត សម្បត្តិ)។

[22] ចម្លើយតប កថាខណ្ឌ ១៤ ដល់ ១៦។

[23] ទាក់ទងនឹងការការបកស្រាយខុសរបស់សហព្រះរាជអាជ្ញាទៅលើការមិនយល់ច្បាស់របស់ Lemkin អំពីភាពយន្តឯកសារដែលពាក់ព័ន្ធ (សូមមើល កថាខណ្ឌ ១៦) មេធាវីការពារក្តីស្នើអង្គជំនុំជម្រះ មើលសារណាដើមនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ សូមមើលឯកសារ **E294** "សំណើសុំទទួលយកភស្តុតាងថ្មី កោះហៅ Rob Lemkin និងចាប់ផ្តើមការស៊ើបអង្កេត"

4. ចំណុចគួរឲ្យយកត់សម្គាល់បំផុតនៃចម្លើយតបរបស់សហព្រះរាជអាជ្ញានោះគឺ ការខកខានក្នុងការឆ្លើយតប ឬក៏មិនទាំងបានលើកឡើងអំពីការរៀបរាប់របស់ ថេត សម្បត្តិ អំពីការគម្រាមកំហែង និងការជ្រៀតជ្រែករបស់រដ្ឋាភិបាលមកលើដំណើរការតុលាការនេះ[24]។ បទសម្ភាសន៍មានតម្លៃជាភស្តុតាងបញ្ជាក់ពីការខកខានក្នុងសំណុំរឿង ០០២/០១ ក្នុងការគោរពសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការកាត់ក្តីដោយតុលាការឯករាជ្យ ដែលជាផ្នែកនៃបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ។ ថេត សម្បត្តិ បានបង្ហាញដោយខ្លួនឯងថា ខ្លួនមានបំណងពិភាក្សាអំពីការជ្រៀតជ្រែក បើទោះបីជាក្នុងវេទិកាសាធារណៈក៏ដោយ។ ស្រដៀងគ្នានេះដែរសហព្រះរាជអាជ្ញាស្នើសុំឲ្យកាត់បន្ថយឲ្យនៅតូចបំផុតនូវភស្តុតាង ដែលមិនអាចប្រកែកបានអំពីការជ្រៀតជ្រែកខាងនយោបាយនៅក្នុងសំណុំរឿង ០០២ ដែលបានលើកឡើងនៅក្នុងសៀវភៅរបស់ចៅក្រម Lemonde តាមរយៈការបង្ហាញពីអវត្តមាននៃឯករាជ្យភាពរបស់តុលាការគ្រាន់តែជា "កំហុសនៃការមិនគោរពវិធានបញ្ញត្តិ" ដែលសហព្រះរាជអាជ្ញាគិតថា នេះវាមិនទាក់ទងទៅនឹងការកាត់ក្តីដោយត្រឹមត្រូវលើរូប នួន ជា ឡើយ[25]។

5. មេធាវីការពារក្តីនៅតែមានបញ្ហាជាមួយនឹងឆន្ទៈរបស់សហព្រះរាជអាជ្ញាទាំងពីរ ដែលជាមន្ត្រីតុលាការ ហើយចូលរួមយ៉ាងសកម្មក្នុងការបិទបាំងអំពីការជ្រៀតជ្រែករបស់រដ្ឋាភិបាលមកលើសុចរិតភាពនៃដំណើរការ និងសិទ្ធិជាមូលដ្ឋានរបស់ នួន ជា ក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌។ វាទំនងជាថា ទស្សនៈវិស័យរបស់តុលាការនេះត្រូវបានបាត់បង់៖ ដោយសារថា ប្រភពដែលគួរឲ្យជឿជាក់ខ្លាំង ហើយដែលព្រះរាជអាជ្ញា និងអង្គជំនុំជម្រះបានពឹងផ្អែកយ៉ាងញឹកញាប់ បានពិពណ៌នាអំពីការយល់ដឹងរបស់ខ្លួនអំពីសាក្សីដែលបានបដិសេធយ៉ាងពិតប្រាកដក្នុងការផ្តល់

---

ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣, កថាខណ្ឌ ៧ ដល់ ៨។ ឯកសារលេខ **E1/223.1** "ប្រតិចារិកសវនាការ" ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៣, ទំព័រ ១២៥៖២២ ដល់ ១២៦៖៧។ ក្នុងចំណោមនោះ សហព្រះរាជអាជ្ញាខកខានមិនបានពន្យល់អំពីសារសំខាន់នៃកង្វះខាតភាសាខ្មែររបស់ Lemkin ដោយសារតែបទសម្ភាសន៍ទាំងអស់ត្រូវបានបកប្រែជាភាសាអង់គ្លេស ហើយអង្គជំនុំជម្រះសាលាដំបូងបានយោងយ៉ាងច្រើនទៅលើភស្តុតាងរបស់អ្នកដែលមិននិយាយភាសាខ្មែរ ដូចជា Philip Short ជាដើម ក្នុងការពិពណ៌ណាអំពីបទសម្ភាសន៍របស់ខ្លួន ហើយថែមទាំងបកស្រាយអត្ថន័យនៃភស្តុតាងជាភាសាខ្មែរទៀត។ សូមមើល ជើងទំព័រ១៨ ខាងលើ។ ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ១២០។

[24] សូមមើលសំណើលើកទី១ កថាខណ្ឌ ១៦។

[25] ចម្លើយតប កថាខណ្ឌ ២៤។

ភស្តុតាង ដោយហេតុថា ភស្តុតាងទាំងនោះនឹងចោទប្រកាន់ផងដែរដល់អ្នកអតីតនៅក្រោមបង្គាប់ដែល*អនុវត្តផ្ទុយ*ពីបញ្ជារបស់ នួន ជា ទៅលើឧក្រិដ្ឋកម្មដែល នួន ជា ត្រូវបានចោទប្រកាន់ ហើយដែលអ្នកទាំងនោះកំពុងមានអំណាច[26]។ បើមើលទៅលើភស្តុតាងនេះ សហព្រះរាជអាជ្ញា ផ្តល់នូវការពន្យាពេលមិនច្បាស់លាស់មួយ ក្នុងពេលដែលការបំបែកសវនាការទាំងមូលបង្ហាញនៅក្នុងសំណុំរឿង ០០២/០២ និងស្វែងរកយ៉ាងសកម្មក្នុងការមិនបង្ហាញចេញអំពីភស្តុតាងទៅលើការជ្រៀតជ្រែករបស់រដ្ឋាភិបាល។ នៅក្នុងកាលៈទេសៈណាក៏ដោយមេធាវីការពារក្តីលើកឡើងថា វិធានការបន្ទាន់ចាំបាច់ត្រូវតែធ្វើឡើង។ ប្រសិនបើសំណុំរឿង ០០២/០១ ជាសវនាការមួយពិតប្រាកដ និង នួន ជា ត្រូវបានសន្មតទុកជាមុនថា គ្មានទោស នោះវិធានការជាបន្ទាន់ដូចគ្នាគួរតែធ្វើឡើងចំពោះអ្នកដែលចូលរួមទាំងអស់ក្នុងដំណើរការ រួមទាំងសហព្រះរាជអាជ្ញា និងចៅក្រម។ បញ្ហានោះគឺមិនមែនតែរឿងការកាត់សេចក្តីដោយយុត្តិធម៌នោះទេ (បើទោះបីវាគួរតែគ្រប់គ្រាន់ក្តី) តែវាជាការគ្មានទោសពិតប្រាកដ។

6. មេធាវីការពារក្តីសូមលើកឡើងថា ការឆ្លើយតបនេះអាចទទួលយកបានអនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអំពីការដាក់ឯកសារ និងស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលអំណះអំណាងដែលបង្ហាញនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងជាថ្មីម្តងទៀតសូមផ្តល់ជូននូវសំណើដែលបានស្នើនៅក្នុងសំណើលើកទី១ និង ទី២ សុំឲ្យពិចារណា និងទទួលយកភស្តុតាងបន្ថែម។

សហមេធាវីការពារក្តី នួន ជា

សុន អរុណ — Victor KOPPE

[26] សូមមើល សំណើលើកទី១ កថាខណ្ឌ ៦ ( ថេត សម្បត្តិ និយាយម្តងហើយម្តងទៀតថា កម្មាភិបាលថ្នាក់ក្រោម "ក្បត់" "ប្រឆាំង" និង "ប្រព្រឹត្តផ្ទុយប្រឆាំងនឹង" នួន ជា ហើយ នួន ជា "មិនមែនផ្តួចផ្តើម" ការកាប់សម្លាប់នៅទួលពោធិជ្រៃទេ)។ ចម្លើយតប កថាខណ្ឌ ១២ (នួន ជា បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមជាមួយ រស់ ញឹម)។